## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

### កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2016
### (ប្រធានបទៈ សេដ្ឋកិច្ច ក្រុមទី២)

ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៦

ឆ្លើយតបតាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន២២រូបដែលមានចំណាប់អារម្មណ៍ទៅលើវិស័យសេដ្ឋកិច្ចនឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី៤ ខែតុលា ជាមួយយុវជនមកពីបណ្តាប្រទេសអាស៊ាន ទីម័រខាងកើត និងប្រទេសឥណ្ឌា ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិតនិងយុវជន រវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើត ដែលហៅកាត់ថា JENESYS 2016។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹង និងទំនុកចិត្តគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសដែលចូលរួម  និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការនិងចំណងមិត្តភាពនាពេលអនាគត។

យុវជនដែលបានអញ្ជើញពីថ្ងៃទី២៥ ខែកញ្ញា នឹងធ្វើទស្សនកិច្ចទៅកាន់ទីក្រុងតូក្យូ និងខេត្តហ្វូគូស៊ីម៉ា ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរ ក្រោមប្រធានបទរង "**តម្លៃម្ហូបអាហារកែច្នៃ**"។ ពួកគេក៏នឹងមានឱកាសធ្វើទស្សនកិច្ចនៅសារមន្ទីរតូក្យូ-អេដូ និងមជ្ឈមណ្ឌលបច្ចេកទេសកសិកម្ម ក៏ដូចជាទទួលបាននូវបទពិសោធស្នាក់នៅផ្ទះជាមួយជនជាតិជប៉ុន ព្រមទាំងទទួលបាននូវបទពិសោធអំពីវប្បធម៌ជប៉ុន។ ចំពោះកម្មវិធីលំអិតមានភ្ជាប់មកជាមួយ។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួមនឹងយល់ដឹងអំពីទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសជប៉ុន និងបណ្តាប្រទេសផ្សេងៗទៀត ហើយបន្ទាប់ពីត្រលប់មកវិញ ពួកគេនឹងចែករំលែកបទពិសោធរបស់ពួកគេទៅកាន់ប្រជាជនកម្ពុជាអោយកាន់តែទូលំទូលាយ។

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162*

*Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*